គណៈកម្មាធិការប្រជាជនខេត្តត្រាវិញ
សាកលវិទ្យាល័យត្រាវិញ

លេខ៖ ២៣៦៥/TB-ĐHTV

សាធារណៈរដ្ឋសង្គមនិយមវៀតណាម
ឯករាជ្យ សេរីភាព សុភមង្គល

*ត្រាវិញ, ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៥*

# សេចក្ដីជូនដំណឹង
# ស្ដីពីការជ្រើសរើសនិស្សិត**អន្តរជាតិ**
# **សិក្សាថ្នាក់បរិញ្ញាបត្រលក្ខណៈពេញម៉ោង ឆ្នាំ២០២៥**

## I. បេក្ខជនដែលត្រូវបានជ្រើសរើស

- បេក្ខជនមានសញ្ជាតិខ្មែរ និងឡាវដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅប្រទេសកម្ពុជា និងប្រទេសឡាវ ឬបេក្ខជនដែលមានសញ្ញាបត្របានទទួលស្គាល់ស្មើនឹងកម្រិតសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិរបស់ប្រទេសវៀតណាម។
- បំពេញតាមលក្ខណៈវិនិច្ឆ័យជ្រើសរើសនិស្សិតណាមួយរបស់សាលា។
- មានសុខភាពគ្រប់គ្រាន់ដើម្បីសិក្សា។
- មិនមានការប្រព្រឹត្តិល្មើសច្បាប់នៃប្រទេសកំណើត និងប្រទេសវៀតណាម។

## II. មុខជំនាញជ្រើសរើស

- បេក្ខជនមើលមុខជំនាញជ្រើសរើស ដែលមានក្នុងបញ្ជីរាយនាមមុខជំនាញបានភ្ជាប់ជាមួយ។
- លក្ខខណ្ឌជ្រើសរើសយោងតាមបទប្បញ្ញត្តិរបស់សាកលវិទ្យាល័យត្រាវិញ។

## III. រយៈពេលបណ្តុះបណ្តាល

- មុខជំនាញវេជ្ជសាស្ត្រ; ទន្តវេទនសាស្ត្រ; វេជ្ជសាស្ត្របង្ការជំងឺ បណ្តុះបណ្តាលក្នុង**៦**ឆ្នាំ។
- មុខជំនាញឱសថសាស្ត្រ បណ្តុះបណ្តាក្នុង**៥**ឆ្នាំ។
- មុខជំនាញផ្សេងៗ បណ្តុះបណ្តាល ពី**៣.៥** ដល់ **៤.៥** ឆ្នាំ។

***កំណត់ចំណាំ៖***
*រយៈពេលបណ្តុះបណ្តាលខាងលើមិនទាន់គិតរយៈពេលបណ្តុះបណ្តាលកម្មវិធីភាសាវៀតណាម នឹងកម្មវិធីបំប៉នចំណេះដឹងស្របតាមឯកទេសដែលបានដាក់ពាក្យ (បណ្តុះបណ្តាលក្នុង**១**ឆ្នាំ)។*

## IV.បែបបទជ្រើសរើស និងលក្ខណ្ឌជ្រើសរើស

**-បែបបទនៃការជ្រើសរើសនិស្សិត៖**

ជ្រើសរើសដោយយោងតាមគោលការណ៍ជ្រើសរើសនិស្សិត នៃសារាចរលេខ ០៨/២០២២/TT-BGDĐT ចុះផ្សាយថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២២

របស់ក្រសួងអប់រំនិងបណ្តុះបណ្តាលនៃប្រទេសវៀតណាម
(លេខកូដនៃបែបបទជ្រើសរើស៖ ៣០១)។

**- លក្ខខណ្ឌជ្រើសរើស៖**

សម្រាប់បេក្ខជនបរទេសមានលទ្ធផលប្រឡងវាស់ស្ទង់សមត្ថភាពជំនាញ
និងសមត្ថភាពភាសាវៀតណាមតាមការកំណត់របស់ក្រសួងអប់រំ
និងបណ្តុះបណ្តាលនៃប្រទេសវៀតណាម
នឹងបានជ្រើសរើសចូលសិក្សាកម្រិតបរិញ្ញាបត្រនៅសាកលវិទ្យាល័យត្រាវិញតាមបណ្តា
ករណីដូចតទៅ៖

**+ ចំពោះបេក្ខជនមិនទាន់បានបញ្ចប់ការសិក្សាភាសាវៀតណាមស្មើកម្រិតB2 (កម្រិត៤/៦)៖** ត្រូវសិក្សាកម្មវិធីភាសាវៀតណាម
និងកម្មវិធីបំប៉នចំណេះដឹងស្របតាមឯកទេសដែលបានដាក់ពាក្យក្នុងរយៈពេល១ឆ្នាំ
តាមការកំណត់របស់សាកលវិទ្យាល័យត្រាវិញ។

**+ ចំពោះបេក្ខជនដែលមានសញ្ញាបត្រមធ្យមសិក្សា បរិញ្ញាបត្ររង បរិញ្ញាបត្រភាសាវៀតណាម ឬបានបញ្ចប់ការសិក្សាភាសាវៀតណាមស្មើកម្រិតB2 (កម្រិត ៤/៦)៖**
សាលាយោងតាមលទ្ធផលនៃការសិក្សា/សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
លទ្ធផលត្រួតពិនិត្យចំណេះដឹង និងសមត្ថភាពភាសាវៀតណាមតាមការកំណត់
ដើម្បីជ្រើសរើសចូលរៀនកម្មវិធីបំប៉នចំណេះដឹងស្របតាមឯកទេសដែលបានដាក់ពាក្យ
ឬចុះឈ្មោះសិក្សាមុខជំនាញ។

**- លក្ខខណ្ឌធានាគុណភាពជ្រើសរើសចូលរៀន៖**

**+ មុខជំនាញ វេជ្ជសាស្ត្រ ទន្តវេទនសាស្ត្រ និងឱសថសាស្ត្រ៖**
បេក្ខជនត្រូវមានពិន្ទុបញ្ចប់ឆ្នាំសិក្សាថ្នាក់ទី១២មានលទ្ធផលល្អណាស់
ឬពិន្ទុប្រឡងបញ្ចប់មធ្យមសិក្សាទុតិយភូមិពី**៨.0/១០**ឡើង ឬ**៨0/១០0**ឡើង
ឬជាប់និទេស**C**ឡើងទៅ ឬពន្ទុពី**៣.២/៤**ឡើង
ឬលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិពីនិទ្ទេសល្អណាស់ឡើងទៅ។
ដើម្បីចូលរៀនមុខជំនាញនិស្សិតត្រូវមានពិន្ទុសិក្សាភាសាវៀតណាមជាមធ្យមភាគពី
**៨.0** ឡើងទៅ។

**+ មុខជំនាញ បច្ចេកទេសមន្ទីរពិសោធន៍ គិលានុបដ្ឋាក វេជ្ជសាស្ត្រស្តារនីតិសម្បទា វេជ្ជសាស្ត្របង្ការជំងឺ បច្ចេកវិទ្យារូបភាពវេជ្ជសាស្ត្រ៖**
បេក្ខជនត្រូវមានពិន្ទុបញ្ចប់ឆ្នាំសិក្សាថ្នាក់ទី១២ជាប់លទ្ធផលល្អបង្គួរ
ឬពិន្ទុប្រឡងបញ្ចប់មធ្យមសិក្សាទុតិយភូមិពី**៦.៥/១០**ឡើង ឬ**៦៥/១០0**ឡើង
ឬជាប់និទេស**D**ឡើងទៅ ឬពន្ទុពី **២.៦/៤**
ឬលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិពីនិទ្ទេសល្អបង្គួរឡើងទៅ។
ដើម្បីចូលរៀនមុខជំនាញនិស្សិតត្រូវមានពិន្ទុសិក្សាភាសាវៀតណាមជាមធ្យមភាគពី**៧.0** ឡើងទៅ។

**+មុខជំនាញផ្សេង៖**

បេក្ខជនត្រូវមានពិន្ទុបញ្ចប់ឆ្នាំសិក្សាថ្នាក់ទី១២ជាប់លទ្ធផលមធ្យមឬពិន្ទុប្រឡងបញ្ចប់មធ្យមសិក្សាទុតិ្តយភូមិពី**៥.០/១០**ឡើង ឬ**៥០/១០០**ឡើង ឬជាប់និទេសEឡើងទៅ ឬពន្ទុពី **២.០/៤** ឬលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិ្តយភូមិពីនិទ្ទេសមធ្យមឡើងទៅ។ ដើម្បីចូលរៀនមុខជំនាញនិស្សិតត្រូវមានពិន្ទុសិក្សាភាសាវៀតណាមជាមធ្យមភាគពី **៥.០** ឡើងទៅ។

**V. សំណុំលិខិតដាក់ពាក្យចូលរៀនរួមមាន**

១. លិខិតដាក់ពាក្យចូលរៀន **(តាមគំរូ)**

២. ច្បាប់ចម្លង ច្បាប់បកប្រែ មានការបញ្ជាក់បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើមនៃសញ្ញាបត្រ លទ្ធផលសិក្សាតាមការកំណត់
នៃកម្រិតសិក្សារបស់ស្ថាប័នមានសមត្ថកិច្ចនៃប្រទេសបញ្ជូនទៅបណ្តុះបណ្តាល។

៣. ច្បាប់ចម្លងលិខិតឆ្លងដែន
មានសុពលភាពគ្រប់សម្រាប់រយៈពេលសិក្សានៅវៀតណាម
ឬយ៉ាងហោច១ឆ្នាំគិតពីថ្ងៃចាប់ផ្តើមចូលមកប្រទេសវៀតណាម។

៤. ច្បាប់ចម្លងវិញ្ញាបនបត្រភាសាវៀតណាម
នៃគ្រឹះស្ថានបណ្តុះបណ្តាលមានសមត្ថកិច្ច
ឬវិញ្ញាបនបត្រអន្តរជាតិអំពីភាសាដើម្បីប្រើប្រាស់នៅសាកលវិទ្យាល័យត្រាវិញ (បើសិនមាន)។

៥. ច្បាប់ចម្លងលិខិតបញ្ជាក់ពីហិរញ្ញវត្ថុដើម្បីធានាក្នុងការសិក្សាស្រាវជ្រាវ និងប្រើប្រាស់នៅវៀតណាម។

៦.
លិខិតបញ្ជាក់សុខភាពចេញដោយស្ថាប័នសុខាភិបាលនៃប្រទេសកំណើតឬប្រទេសវៀតណាម (មិនលើសពី៦ខែ)។

*កំណត់ចំណាំ៖ ឯកសារត្រូវបានបកប្រែជាភាសាវៀតណាម ឬអង់គ្លេស*

**VI. ថ្លៃសិក្សា**

**១. ដំណាក់កាលសិក្សាទី១៖** កម្មវិធីបណ្តុះបណ្តាលភាសាវៀតណាម និងបំប៉នចំណេះដឹងស្របតាមឯកទេសដាក់ពាក្យ៖ **១២.៥០០.០០** ដុង (≈ **៥២០** USD)។

**២. ដំណាក់កាលសិក្សាទី២ (កម្មវិធីសិក្សាជំនាញ)៖**

* មុខជំនាញ វេជ្ជសាស្ត្រ ទន្តវេទនសាស្ត្រ វេជ្ជសាស្ត្របង្ការជំងឺ៖ **៦៥.០០០.០០០** ដុង/ឆ្នាំ (≈ **២.៦១០** USD/ឆ្នាំ)។

- មុខជំនាញដទៃទាក់ទងនឹងវិស័យវិទ្យាសាស្ត្រសុខាភិបាល៖ **៤៧.០០០.០០០** ដុង/ឆ្នាំ (≈ **១.៩០០** USD/ឆ្នាំ)។
- មុខជំនាញផ្សេងៗ៖ **២៧.៣០០.០០០** ដុង – **៣០.៣០០.០០០** ដុងក្នុង១ឆ្នាំ (≈ **១.០៩៥** USD – **១.២១៥** USD/ឆ្នាំ)។

- ***កំណត់ចំណាំ៖*** *ថ្លៃសិក្សាត្រូវបង់ជូនសាលាពីរលើកក្នុងមួយឆ្នាំ។ សម្រាប់ឆ្នាំសិក្សាបន្តបន្ទាប់ថ្លៃសិក្សានឹងកើនឡើងប្រមាណ ១០%។*

**៣. ចំណាយផ្សេងៗ៖** ចំណាយលើការស្នាក់នៅ ទិដ្ឋាការ បណ្ណធានារ៉ាប់រង ថ្លៃបញ្ជាក់សមមូលសញ្ញាបត្រ... សាលានឹងណែនាំបេក្ខជនក្នុងការបំពេញបែបបទនានាតាមការកំណត់ បេក្ខជន**ផ្ទាល់ជាអ្នក**ចំណាយថ្លៃសិក្សា និងចំណាយផ្សេងៗទៀតក្នុងរយៈពេលសិក្សានៅសាលា។

**VII. កាលបរិច្ឆេទទទួលពាក្យ**

- **ទទួលពាក្យ៖** ចាប់ពីថ្ងៃចុះផ្សាយ រហូតដល់ថ្ងៃទី**៣០/០៩/២០១៥។**
- ប្រកាសលទ្ធផល (បម្រុង)៖ **១៥/១០/២០១៥។**
- ពេលចូលរៀន (បម្រុង)៖ **១៥/១១/២០១៥។**

**VIII. ព័ត៌មានទំនាក់ទំនង**

គណៈកម្មការជ្រើសរើសនិស្សិតអន្តរជាតិនៃសាកលវិទ្យាល័យត្រាវិញ.

**អាស័យដ្ឋាន៖** លេខ ១២៦ វិថី ង្វៀនធៀនថាញ់ សង្កាត់លេខ៥ ក្រុងត្រាវិញ ខេត្តត្រាវិញ។

**លេខទូរស័ព្ទ៖** 2943 855 246

**Hotline/ Telegram:** +84375080875 (លោកគ្រូ សុខុម)

**អ៊ីមែល៖** **apply@tvu.edu.vn**

សាកលវិទ្យាធិការ